ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៤២២ អ.ក
ចុះថ្ងៃទី ០៨.វិច្ឆិកា.២០១៧
សាលក្រមលេខ:០៣៤ "ណ"
ចុះថ្ងៃទី ២៦-០២-២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**

សាលាដំបូងខេត្តកណ្តាល បានបើកសវនាការជាសាធារណៈ នាថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២០ ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្ត កណ្តាល

**តំណាងអយ្យការ**

លោកស្រី [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១៤២២ អក ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលមានជនជាប់ចោទ:

១.ឈ្មោះ [redacted] មឿន ភេទ ប្រុស អាយុ ៥៧ឆ្នាំ មុខរបរ គ្រូបង្រៀង ជនជាតិខ្មែរ មានទីកន្លែងកំណើត និង ទីលំនៅ ភូមិ [redacted] ខេត្ត កណ្តាល ឪពុកឈ្មោះ [redacted] យ៉ន (ស្លាប់) ម្តាយឈ្មោះ [redacted] យុន (ស្លាប់) ប្រពន្ធឈ្មោះ [redacted] គឹមស្រេង មានកូន ៥នាក់ ទោសពីមុនគ្មាន ជានីតិជន (ក្រៅឃុំ)។

ជាប់ចោទពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ ស្វាយអាត់លើ ឃុំ ព្រែកតាមាក់ ស្រុក អង្គស្នួល ខេត្ត កណ្តាល កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៩ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនរងគ្រោះឈ្មោះ [redacted] ឈុនលី កើតឆ្នាំ ១៩៨០ មានទីលំនៅ ភូមិស្វាយអាត់លើ ឃុំ ព្រែកតាមាក់ ស្រុក ខ្សាច់កណ្តាល ខេត្ត កណ្តាល។

-មេធាវី [redacted] ការពារសិទ្ធិឱ្យ ដើមបណ្តឹង ឬ ជនរងគ្រោះឈ្មោះ [redacted] ឈុនលី។

*អង្គហេតុនៃរឿងមានដូចតទៅ៖*

កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៧ វេលាម៉ោង ១៨ និង ៣០នាទី ឈ្មោះ [redacted] ឈុនលី និង ឈ្មោះ [redacted] មឿន បានទៅផឹកកាហ្វេ និង មើលប្រដាល់ ជាមួយគ្នា ពេលមើលដល់គូប្រដាល់ថៃ ខ្មែរ ឈ្មោះ [redacted] ឈុនលី និង ឈ្មោះ [redacted] មឿន មានការទាស់សំដីគ្នា ហើយឈ្មោះ [redacted] មឿន បានវាយឈ្មោះ ហាក់ ឈុនលីមួយដៃ ចំគុម្ពត្រចៀកខាងស្តាំ។

បានឃើញ ដីកាដំណោះស្រាយលេខ ៨៣៩ ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៩។

បានឃើញ ដីកាចាត់តាំង ចៅក្រមជំនុំជម្រះ លេខ ៩០៧ ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩ ។



Scanned with CamScanner

## នាពេលសវនាការ

-អានចម្លើយជនជាប់ចោទឈ្មោះ [redacted] មឿន ថា: នៅថ្ងៃកើតហេតុខ្លួនមិនបាន វាយឈ្មោះ [redacted] ឈុនលីនោះទេ គឺគ្រាន់តែប្រតាយប្រតប់គ្នា មិនមាននណាម្នាក់ដួល នោះទេ ហើយឈ្មោះ [redacted] ជ្រឿន បានឃើញហេតុការណ៍នោះដែរ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈុនលី ឆ្លើយថា: ដើមហេតុដំបូង គឺមកពី មើលប្រដាល់ ដោយជនជាប់ចោទកាន់ជើងថៃ ចំណែកខ្លួនកាន់ជើងខ្មែរ ដោយមានការ ជជែកគ្នា ដោយមានការខឹង គាត់បានទាញកៅអី បំរុងវាយខ្លួន តែគេឃាត់ ហើយគាត់ ក៏បានប្រានខ្លួន តែខ្លួនពុំបានតបនោះទេ ហើយខ្លួនក៏បានទៅរកមេភូមិ ដើម្បីអោយ ជួយដោះស្រាយតែមេភូមិ គាត់ថាជាងរឿងព្រហ្មទណ្ឌគាត់ក៏ទៅប៉ុស្តិ៍។ ឈ្មោះ [redacted] មឿន វាយនឹងដៃចំគុម្ពត្រចៀក មិនមានរបួសទេ តែខ្លួនឈឺចាប់មីថ្ងៃដែរ ទើបខ្លួនមិនបានធ្វើការ បីថ្ងៃ។ ខ្លួនបានចំណាយលុយប្រហែល ២០ ដុល្លារអាមេរិក។ ខ្លួនទាមទារ ២ ០០០ (ពីរពាន់) ដុល្លារអាមេរិក ដោយសារប៉ះពាល់កិត្តិយស និង ខាតពេលវេលាចូលតុលាការ។ ខ្លួនគិតថាគាតមានលទ្ធភាពសង តែគាត់មិនសង។ ពេលគាត់វាយខ្លួនហើយ គាត់បាន ជំរុញឱ្យខ្លួនប្ដឹងទៀត។ ក្រោយមកខ្លួនបានជួបជាមួយឈ្មោះ [redacted] មឿន ហើយគាត់បាន និយាយ ថាហ្អែងចង់ប្ដឹងដល់ណាប្ដឹងទៅធ្វើអីអញ។ នៅពេលវាយគឺមានមនុស្សច្រើន ហើយ ពេលនោះខ្លួនមានអារម្មណ៍ឈឺចាប់ដែរ។ ពីមុនមកគាត់ធ្លាប់មានរឿងជាមួយគេ ដែរតែ ដោយសារគេពុំមានលទ្ធភាព ប្ដឹង។ ខ្លួនពុំមានឯកសារបញ្ជាក់ពីស្នាមរបួសនោះ ទេ។ ខ្លួន ទាមទារ ២ ០០០ (ពីរពាន់)ដុល្លារអាមេរិក។

-សាក្សីឈ្មោះ [redacted] រុំ ឆ្លើយថា: រឿងកើតឡើងពីរឿងប្រដាល់ ដោយម្នាក់កាន់ជើង ថៃ និង ម្នាក់កាន់ជើងខ្មែរ។ ខ្លួនបានឃើញលោកគ្រូ [redacted] មឿន ទាញកៅអីមកក្រោយ។ ខ្លួន អង្គុយពីក្រោយឈ្មោះ [redacted] មឿន។ ខ្លួនឃើញឈ្មោះ [redacted] មឿន យាវាយនឹងដៃ។ ការ វាយពុំមានចេញឈាមនោះទេ។ ខ្លួនត្រូវជាបងប្អូនទាំងសងខាង។ ពេលវាយហើយខ្លួនពុំ បានពិនិត្យឈ្មោះ [redacted] លី នោះទេ ខ្លួនពុំឃើញស្នាមជាំនោះទេ។

-មេធាវីការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា: ជនជាប់ចោទ ជាគ្រូ បង្រៀន ដែលអំពើរបស់ជនជាប់ចោទវាយទៅលើជនរងគ្រោះ នៅកន្លែងសាធារណៈ បានប៉ះពាល់ខ្លាំងដល់កិត្តិយល់ជនរងគ្រោះ និង ជាគំរូមិនល្អដល់ក្មេងជំនាន់ក្រោយ ដូច នេះស្នើសុំតុលាការ ផ្តន្ទាទោសលើជនជាប់ចោទ និង សម្រេចពីសំណង ដូចការទាមទា របស់ដើមបណ្ដឹង ។

-តំណាងអយ្យការសន្និដ្ឋាន: មានភស្តុតាង និង ពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] មឿន ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ ស្វាយអាត់លើ ឃុំ ព្រែកតា មាក់ ស្រុក អង្គស្នួល ខេត្ត កណ្ដាល កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៩ តាមបញ្ញត្តិ មាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា:

ក.អំពីពិរុទ្ធភាព៖

១-តាមដីកាដំណោះស្រាយលេខ ៨៣៩ ចុះថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៩ បានសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] មឿន ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិស្វាយអាត់លើ ឃុំ ព្រែកតា មាក់ ស្រុក អង្គស្នួល ខេត្ត កណ្ដាល កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៩ តាមបញ្ញត្តិ មាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] មឿន ឱ្យដឹងថា: នៅថ្ងៃកើតហេតុខ្លួនមិនបាន វាយឈ្មោះ ហាក់ ឈុនលីនោះទេ គឺគ្រាន់តែប្រតាយប្រតប់គ្នា មិនមាននណាម្នាក់ដួល នោះទេ ហើយឈ្មោះ [redacted] ជឿន បានឃើញហេតុការណ៍នោះដែរ។

៣-តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ហាក់ ឈុនលី ឱ្យដឹងថា: ដើមហេតុដំបូង គឺមកពីមើលប្រដាល់ ដោយជនជាប់ចោទកាន់ជើងថៃ ចំណែកខ្លួនកាន់ជើងខ្មែរ ដោយមានការ ជជែកគ្នា ដោយមានការខឹង គាត់បានទាញកៅអី បំរុងវាយខ្លួន តែគេឃាត់ ហើយគាត់ ក៏បានប្រានខ្លួន តែខ្លួនពុំបានតបនោះទេ ហើយខ្លួនក៏បានទៅរកមេភូមិ ដើម្បីអោយ ជួយដោះស្រាយតែមេភូមិ គាត់ថាជាងរឿងព្រហ្មទណ្ឌគាត់ក៏ទៅប៉ុស្ដិ៍។ ឈ្មោះ [redacted] មឿន វាយនឹងដៃចំគុម្ពត្រចៀក មិនមានរបួសទេ តែខ្លួនឈឺចាប់បីថ្ងៃដែរ ទើបខ្លួនមិនបានធ្វើការ បីថ្ងៃ។ ខ្លួនបានចំណាយលុយប្រហែល ២០ ដុល្លារអាមេរិក។ ខ្លួនទាមទារ ២ ០០០ (ពីរពាន់) ដុល្លារអាមេរិក ដោយសារប៉ះពាល់កិត្តិយស និង ខាតពេលវេលាចូលតុលាការ។ ខ្លួនគិតថាគាតមានលទ្ធភាពសង តែគាត់មិនសង។ ពេលគាត់វាយខ្លួនហើយគាត់បាន ជំរុញឱ្យខ្លួនប្ដឹងទៀត។ ក្រោយមកខ្លួនបានជួបជាមួយឈ្មោះ [redacted] មឿន ហើយគាត់បាន និយាយ ថាហ្អែងចង់ប្ដឹងដល់ណាប្ដឹងទៅធ្វើអីអញ។ នៅពេលវាយគឺមានមនុស្សច្រើន ហើយ ពេលនោះខ្លួនមានអារម្មណ៍ឈឺចាប់ដែរ។ ពីមុនមកគាត់ធ្លាប់មានរឿងជាមួយគេ ដែរតែដោយសារគេពុំមានលទ្ធភាពប្ដឹង។ ខ្លួនពុំមានឯកសារបញ្ជាក់ពីស្នាមរបួសនោះ ទេ។ ខ្លួន ទាមទារ ២ ០០០ (ពីរពាន់)ដុល្លារអាមេរិក។

៤-តាមចម្លើយសាក្សីឈ្មោះ [redacted] រុំ ឱ្យដឹងថា: រឿងកើតឡើងពីរឿងប្រដាល់ ដោយម្នាក់កាន់ជើង ថៃ និង ម្នាក់កាន់ជើងខ្មែរ។ ខ្លួនបានឃើញលោកគ្រូ [redacted] មឿន ទាញកៅអីមកក្រោយ។ ខ្លួន អង្គុយពីក្រោយឈ្មោះ [redacted] មឿន។ ខ្លួនឃើញឈ្មោះ [redacted] មឿន យាវាយនឹងដៃ។ ការ វាយពុំមានចេញឈាមនោះទេ។ ខ្លួនត្រូវជាបងប្អូនទាំងសងខាង។ ពេលវាយហើយខ្លួនពុំ បានពិនិត្យឈ្មោះ [redacted]លី នោះទេ ខ្លួនពុំឃើញស្នាមជាំនោះទេ។

៥-មេធាវីការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា: ជនជាប់ចោទ ជាគ្រូបង្រៀន ដែលអំពើរបស់ជនជាប់ចោទវាយទៅលើជនរងគ្រោះ នៅកន្លែងសារធារណ: បានប៉ះពាល់ខ្លាំងដល់កិត្តិយស់ជនរងគ្រោះ និង ជាគំរូមិនល្អដល់ក្មេងជំនាន់ក្រោយ ដូចនេះស្នើសុំតុលាការ ផ្ដន្ទាទោសលើជនជាប់ចោទ និង សម្រេចពីសំណង ដូចការទាមទារបស់ដើមបណ្ដឹង ។

៦-តំណាងអយ្យការសន្និដ្ឋាន: មានភស្តុតាង និង ពិរុទ្ធភាព លើជនជាប់ចោទឈ្មោះ [redacted] មឿន ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ ស្វាយអាត់លើ ឃុំ ព្រែកតាមាក់ ស្រុក អង្គស្នួល ខេត្ត កណ្ដាល កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៩ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

៧-ជនជាប់ចោទឈ្មោះ [redacted] មឿន ពិតជាបានវាយទៅលើជនរងគ្រោះឈ្មោះហាក់ ឈុនលី នឹងដៃត្រូវចំគុម្ពត្រជៀក នៅខណ:ពេលមើលប្រដាល់ ដែលមានមនុស្សជាច្រើន។

៨-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] មឿន បានធ្វើឲ្យ ប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និង សណ្តាប់ធ្នាប់សង្គម ដូចនេះត្រូវតែទទួលខុសត្រូវ ចំពោះមុខច្បាប់។

៩.អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានធាតុផ្សំគ្រប់គ្រាន់ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

១០-ជនជាប់ចោទឈ្មោះ [redacted] មឿន ជាសមត្ថជនមានស្មារតី ធម្មតាអាចយល់ដឹងពីបច្ច័យ និង ព្យសនកម្ម ដែលកើតឡើងពីអំពើរបស់ខ្លួន ដែលបាន ប្រព្រឹត្ត។

១១-មានភស្តុតាងបញ្ជាក់ពីពិរុទ្ធលើជនជាប់ចោទ ឈ្មោះ [redacted] មឿន (មានសាវតាជាតិគ្រប់គ្រាន់ដូចខាងលើ) ពី បទហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ ស្វាយអាត់លើ ឃុំ ព្រែកតា មាក់ ស្រុក អង្គស្នួល ខេត្ត កណ្តាល កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៩ តាមបញ្ញត្តិ មាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

ខ.អំពីទោស៖

## ហេតុដូច្នេះ-តុលាការ

## <u>សម្រេច</u>

១.ផ្តន្ទាទោសលើជនជាប់ចោទ

ឈ្មោះ [redacted] មឿន (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារ រយៈពេល ១ (មួយ) ឆ្នាំ តែទោសនេះត្រូវព្យួរ

ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ ស្វាយអាត់លើ ឃុំ ព្រែកតា មាក់ ស្រុក អង្គស្នួល ខេត្ត កណ្តាល កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៩ តាមបញ្ញត្តិ មាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឱ្យជនជាប់ចោទ ឈ្មោះ [redacted] មឿន សងសំណងជំងឺចិត្តជាប្រាក់ ២ ០០០ ០០០ (ពីរលាន) រៀល ទៅដើមបណ្តឹង ឬ ជនរងគ្រោះ ឈ្មោះ [redacted] ឈុនលី ការទាមទារលើសពីនេះច្រានចោល ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២០ និង ប្រកាសជាសាធារណៈ ២៦ ខែ កុម្ភៈ ឆ្នាំ ២០២០ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] មឿន និង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈុនលី ទុកសិទ្ធិប្តឹង ឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** | **តំណាងអយ្យការ** | **ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]

[redacted]



Scanned with CamScanner